# សេចក្ដីថ្លែងការណ៍រួម
# ក្នុងវេទិកាសហគមន៍ក្រីក្រក្នុងទីក្រុងលើកទី ៦
# ក្រោមប្រធានបទ "សិទ្ធិមានលំនៅឋានសមរម្យ និងការអភិវឌ្ឍទីក្រុង ដោយមានការចូលរួម"

យើងខ្ញុំទាំងអស់គ្នាជាប្រជាពលរដ្ឋមកពីសហគមន៍នានានៅក្នុងរាជធានីភ្នំពេញដែលកំពុងប្រឈមនឹងអសុវត្ថិភាពដីធ្លី និងលំនៅឋានដោយសារការអភិវឌ្ឍទីក្រុងដោយកង្វះនូវតម្លាភាព។

យោងតាមរបាយការណ៍របស់អង្គការសមាគមធាងត្នោតស្ដីពី ការស្ទង់មតិក្នុងរាជធានីភ្នំពេញ ដែលសិក្សាពីទីតាំងលំនៅឋានក្រីក្រ បានរកឃើញថា យ៉ាងហោចណាស់ មានសហគមន៍ក្រីក្រប្រមាណ២៧៧ ទីតាំងក្នុងខណ្ឌទាំង១២ នៃរាជធានីភ្នំពេញ។ របាយការណ៍ដដែលរកឃើញថា ៨៣% នៃទីតាំងទាំងនេះ មិនមានឯកសារផ្លូវការជាលាយលក្ខណ៍អក្សរដើម្បីកំណត់ពីស្ថានភាពដីធ្លីរបស់ពួកគេទេ ខណៈ៧៥% នៃទីតាំងមិនទាន់មានប្លង់កម្មសិទ្ធិកាន់កាប់ស្របច្បាប់ផងដែរ។ លើសពីនេះ មានសហគមន៍ចំនួន៤១ ទីតាំងកំពុងប្រឈមនឹងការបណ្ដេញចេញ ឬរងសម្ពាធក្នុងការឱ្យផ្លាស់ប្ដូរលំនៅឋាន។ ស្ថានភាពនេះបានបង្ហាញថា សហគមន៍ក្រីក្រក្នុងទីក្រុងមិនទាន់មានសុវត្ថិភាពដីធ្លី និងលំនៅឋាន ដោយសារមិនទាន់មានសិទ្ធិកាន់កាប់ស្របច្បាប់ ឬទទួលស្គាល់ពីអាជ្ញាធរពាក់ព័ន្ធនៅឡើយ។

គួរគាត់សម្គាល់ថា ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ប្រជាពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញច្រើនជាង ១០ភាគរយ ត្រូវបានជម្លៀសចេញពីលំនៅឋានរបស់ខ្លួន។ ប្រជាពលរដ្ឋទាំងនោះត្រូវបានជម្លៀសចេញពីលំនៅឋានរបស់ខ្លួនក្រោមហេតុផលដើម្បីធ្វើការអភិវឌ្ឍកែលម្អសោភ័ណ្ឌភាពទីក្រុង ការរៀបចំសណ្ដាប់ធ្នាប់ សន្តិសុខ និងសុវត្ថិភាពសង្គម។ ប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុងបានក្លាយជាជនរងគ្រោះខ្លាំងជាងគេនៅពេលដែលមានការអភិវឌ្ឍក្រោមហេតុផលទាំងនេះ។ ជាក់ស្ដែង កន្លងមកក្នុងរាជធានីភ្នំពេញ ក៏ដូចជានៅតំបន់ជនបទមួយចំនួនក្នុងប្រទេសកម្ពុជា គឺពួកយើងដែលជាម្ចាស់ផ្ទះ ជាម្ចាស់ដីមិនទទួលបានផលអ្វីពីការអភិវឌ្ឍនោះទេ។ ផ្ទុយទៅវិញ យើងត្រូវបានគេបង្ខំឱ្យចាកចេញពីលំនៅឋានរបស់ខ្លួនទៅរស់នៅក្នុងតំបន់ឆ្ងាយពីទីក្រុង ឬនៅតំបន់ជាយក្រុងដែលមិនទាន់មានសេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់នៅឡើយ។ ជារឿយៗ តំបន់ដែលពួកយើងត្រូវបានជម្លៀសទៅនោះ នៅឆ្ងាយពីកន្លែងប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកយើង ហើយវាបានក្លាយជាឫសគល់ដ៏ធំមួយនៃភាពក្រីក្រតោកយ៉ាក។

ដោយមានបទពិសោធន៍នៃការរំលោភបំពានយ៉ាងអយុត្តិធម៌បែបនេះ ពួកយើងជាប្រជាពលរដ្ឋនៅក្នុងទីក្រុងបានធ្វើការទាមទារឱ្យមានការអភិវឌ្ឍទីក្រុង និងប្រទេសជាតិប្រកបដោយតម្លាភាព ការចូលរួម សមភាព និងយុត្តិធម៌។ ប៉ុន្តែជាអកុសល ការខិតខំប្រឹងប្រែងធ្វើការទាមទារនេះ តែងតែត្រូវបានអាជ្ញាធរ និងមន្ត្រីរាជរដ្ឋាភិបាលដែលពាក់ព័ន្ធមួយចំនួនបានព្យាយាមទប់ស្កាត់ គំរាមកំហែង និងពេលខ្លះបានឈានទៅដល់ការបង្កហិង្សាមានរបួសស្នាម និងចាប់ដាក់ពន្ធនាគារផងដែរ។ កន្លងមក អ្នកតស៊ូមតិ ម្ចាស់ផ្ទះ ឬដីធ្លីមួយចំនួនត្រូវបានទទួលរងការប្រើប្រាស់អំពើហិង្សាពីអាជ្ញាធរមានសមត្ថកិច្ច ការចាប់ខ្លួន ឃាត់ខ្លួន និងឃុំខ្លួនក្នុងពន្ធនាគារដោយ អយុត្តិធម៌បំផុត។ ម្យ៉ាងវិញទៀត កន្លងមក រាជរដ្ឋាភិបាល ជាពិសេស សាលារាជធានីភ្នំពេញបានរៀបចំគម្រោងអភិវឌ្ឍន៍ ដោយមិនបានប្រឹក្សាយោបល់ពេញលេញជាមួយយើងខ្ញុំជាប្រជាពលរដ្ឋក្រីក្រ និងជាជនរងផលប៉ះពាល់ទេ ផ្ទុយទៅវិញ ពួកយើងខ្ញុំត្រូវបានគំរាមកំហែង និងបង្ខំឱ្យចាកចេញដោយមិនផ្ដល់

សំណាងសមរម្យឡើយ។ ដោយមើលឃើញរូបភាពមិនប្រក្រតីទាំងនេះ យើងខ្ញុំជាប្រជាពលរដ្ឋរស់នៅក្នុងទីក្រុងទទូចស្នើសុំប្រមុខរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ មេត្តាជ្រាប និងជួយដោះស្រាយសេចក្តីត្រូវការពិតប្រាកដរបស់យើងខ្ញុំ។

ក្នុងឱកាសវេទិកាសហគមន៍ក្រីក្រក្នុងទីក្រុងលើកទី៦ ឆ្នាំ២០១៩ នេះ យើងខ្ញុំទាំងអស់គ្នាទទូចស្នើសុំរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធគោរព និងការពារសិទ្ធិរបស់យើងខ្ញុំជាប្រជាពលរដ្ឋក្រីក្រ ថាជាអ្នកមានសិទ្ធិរស់នៅដោយសមរម្យ និងមានសេចក្តីថ្លៃថ្នូរ ដូចប្រជាពលរដ្ឋក្នុងទីក្រុងដ៏ទៃទៀតដែរ។ យើងខ្ញុំទាំងអស់គ្នាមិនជំទាស់ចំពោះការអភិវឌ្ឍទេ ប៉ុន្តែពួកយើងត្រូវតែទទួលបានផលប្រយោជន៍ពីគម្រោងអភិវឌ្ឍន៍ទាំងនោះ។

ដូច្នេះហើយ នាឱកាសវេទិកាសហគមន៍ក្រីក្រក្នុងទីក្រុងឆ្នាំ២០១៩នេះ យើងខ្ញុំទាំងអស់គ្នាសូមអំពាវនាវឱ្យ៖

- រាជរដ្ឋាភិបាល អាជ្ញាធរគ្រប់ជាន់ថ្នាក់ និងស្ថាប័នពាក់ព័ន្ធនានានៃរាជរដ្ឋាភិបាលកម្ពុជាមេត្តាទទួលស្គាល់ និងអនុវត្តន៍ឱ្យបាននូវសិទ្ធិមានលំនៅឋានសមរម្យ ដើម្បីឱ្យមានការអភិវឌ្ឍសម្រាប់ទាំងអស់គ្នា។
- រាជរដ្ឋាភិបាលអនុវត្តន៍ច្បាប់ឱ្យមានប្រសិទ្ធិភាព និងបញ្ឈប់ការបណ្តេញចេញដោយបង្ខំ ការប្រើអំពើហិង្សា និងបញ្ឈប់ការប្រើប្រាស់ប្រព័ន្ធតុលាការគាបសង្កត់លើប្រជាពលរដ្ឋ ជាពិសេសគឺសកម្មជនដីធ្លី និងលំនៅឋាន។
- សាលារាជធានីភ្នំពេញផ្តល់ និងគាំទ្រក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងផ្តល់សេវាកម្មកាន់តែប្រសើរឡើងក្នុងទីតាំងលំនៅឋានក្រីក្រ ដូចជាប្រព័ន្ធលូបង្ហូរទឹក ការប្រមូលសំរាម និងការតភ្ជាប់បណ្តាញទឹកនិងអគ្គិសនីរបស់រដ្ឋ។
- អាជ្ញាធរពាក់ព័ន្ធ ជាពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសាលារាជធានីភ្នំពេញ អនុវត្តន៍គោលនយោបាយផ្សេងៗពាក់ព័ន្ធនឹងលំនៅឋានឱ្យមានប្រសិទ្ធិភាព ដោយផ្តោតលើការខិតខំប្រឹងប្រែង កែលម្អទីតាំលំនៅឋានសហគមន៍ក្រីក្រនៅនឹងកន្លែងជាជម្រើសចម្បង និងជម្រើសផែនការសុវត្ថភាពដីធ្លីផ្សេងៗទៀតដែលអាចធ្វើបាន ហើយចៀសវាងឱ្យបាននូវការបណ្តេញចេញពីលំនៅឋានទាំងបង្ខំ។

<u>ឈ្មោះសហគមន៍ដែលគាំទ្រសេចក្តីថ្លែងការណ៍</u>៖

1. សហគមន៍ទួលសង្កែបី
2. សហគមន៍ផ្លូវរថភ្លើង
3. សហគមនរលួសជើងឯង
4. សហគមន៍ជើងឯកក្រុម ៣
5. សហគមន៍ជើងឯកក្រុម ៤
6. សហគមន៍ស្ទឹងមានជ័យ
7. សហគមន៍ព្រែកតាគង់
8. សហគមន៍បុរីកីឡា
9. សហគមន៍ថ្មគោល

10. សហគមន៍បឹងឈូកអេ
11. សហគមន៍មិត្តភាព
12. សហគមន៍ជ្រោយចង្វារ
13. សហគមន៍សំរោងត្បូង
14. សហគមន៍បឹងឈូក
15. សហគមន៍វត្តប្រយូវង្ស
16. សហគមន៍បឹងត្របែក
17. សហគមន៍បឹងកក់
18. សហគមន៍ភូមិ២៣
19. សហគមន៍ទួលសង្កែអេ
20. សហគមន៍ត្រពាំងរាំងថ្មី
21. សហគមន៍សែនរីករាយ
22. សហគមន៍សំរោងមានជ័យ
23. សហគមន៍ផ្សារតូចអា
24. សហគមន៍និរោធបឹងឈូក
25. សហគមន៍ក្រោលគោ
26. សហគមន៍៩២
27. សហគមន៍បុរីមិត្តភាព
28. សហគមន៍ឬស្សីស្រស់
29. សហគមន៍ទំនប់២
30. សហគមន៍សាមគ្គីរុងរឿង
31. សហគមន៍ព្រៃកតាគង់ផ្លូវ៦០ម៉ែត្រ
32. សហគមន៍ព្រៃកតាគង់៣
33. សហគមន៍ស្មាសាន
34. សហគមន៍បុរីដើមស្រល់
35. សហគមន៍ស្ត្រីឃ្លាំងសាំង